**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តស្វាយរៀង**

**ស្រុករំដួល**

**ឃុំសង្កែ**

**លេខ:** 001..........

# ដីកា

## ស្តីពី

## ការបង្ការ និងទប់ស្កាត់អំពើហិង្សារួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការ អំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំសង្កែ ស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៥ ។
- យោងលទ្ធផលសិក្ខាសាលាស្តីពី " វិធានការរួមស្តីពីការបង្ការនិងទប់ស្កាត់អំពើហិង្សាលើដៃគូស្និទ្ធស្នាល ដែលជាប់ពាក់ព័ន្ធនឹងគ្រឿងស្រវឹង" ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី១៥ខែកក្កដា ឆ្នាំ២០១៥ ។

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និង ប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋជារួមក្នុងឃុំសង្កែ ដូច្នេះក្រុមប្រឹក្សាឃុំសង្កែ

សម្រេច

**ប្រការ១**៖ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រីសិទ្ធិកុមារនិងបង្ការអំពើហិង្សាលើដៃគូស្និទ្ធស្នាល ព្រមទាំងលើកកម្ពស់សុខុមាលភាពនិងប្រាក់ចំណូលប្រជាពលរដ្ឋក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់ និង សុវត្ថិភាពក្នុងឃុំសង្កែទាំងមូល ។

**ប្រការ២**៖ដីកានេះមានវិសាលភាពអនុវត្តទៅលើ អ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា

ផលគ្រឿងស្រវឹងទៅឲ្យជនឬនៅទីកន្លែងមួយចំនួនក្នុងឃុំសង្កែ ដែលបានកំណត់ក្នុងដីនេះ ។

**ប្រការ៣៖**ហាមប្រើឲ្យទិញ ឬលក់គ្រឿងស្រវឹងឲ្យក្មេងចាប់ពីអាយុ១៥ឆ្នាំចុះក្រោម ។ បើជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ (មួយម៉ឺនរៀល) ទៅ៥០០០០៛ (ប្រាំម៉ឺនរៀល) ។

**ប្រការ៤៖**រាល់ការផលិតគ្រឿងស្រវឹងត្រូវមានការត្រួតពិនិត្យ និង អនុញ្ញាតដោយមេឃុំ ។

បើជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ ( មួយម៉ឺនរៀល) ទៅ ៣០០០០៛ (បីម៉ឺនរៀល) ។

**ប្រការ៥៖**អ្នកដែលប្រើប្រាស់គ្រឿងស្រវឹងហើយដើរស្រែកឡូឡា ឬ ជេរប្រមាថអ្នកដទៃ ឬ ប្រើឧបករណ៍បំពងសំឡេងចាប់ពីម៉ោង១១:០០នាទី យប់តទៅត្រូវផាកពិន័យពី៣០០០០៛(បីម៉ឺនរៀល)ទៅ ៥០០០០៛ប្រាំម៉ឺន) (រៀល ។

**ប្រការ៦៖**មិនអនុញ្ញាតអោយមានការលក់ផលិតផលគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹងគ្រប់ប្រភេទនៅ តាមបរិវេណវត្តអារាម សាលារៀន មណ្ឌលសុខភាព ។

បើជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី២០០០០៛ (ពីរម៉ឺនរៀល)ទៅ ៥០០០០៛ (ប្រាំម៉ឺនរៀល) ។

**ប្រការ៧៖** អ្នកពិសារគ្រឿងស្រវឹង ដែលបង្កហិង្សាត្រូវផាកពិន័យជាទឹកប្រាក់ពី៥០០០០៛(ប្រាំម៉ឺនរៀល) ទៅ១០០០០០៛(មួយសែនរៀល) ។ ចំពោះបទឧក្រិដ្ឋត្រូវចាត់វិធានការទៅតាមផ្លូវច្បាប់ ។

**ប្រការ៨៖**មិនត្រូវលក់អោយឬទិញគ្រឿងស្រវឹង ចំពោះអ្នកដែលស្ថិតក្នុងស្ថានភាពស្រវឹងជោគជាំ ។

បើជនណាប្រព្រឹត្តផ្ទុយនឹងប្រការនេះ នឹងត្រូវទទួលផាកពិន័យជាប្រាក់ពី៣០០០០៛(បីម៉ឺនរៀល)ទៅ ៥០០០០៛(ប្រាំម៉ឺនរៀល) ។

**ប្រការ៩៖**ការផាកពិន័យ និង ការចុះត្រួតពិនិត្យជាតួនាទីរបស់ក្រុមប្រឹក្សាឃុំ និង នគរបាលប៉ុស្តិ៍រដ្ឋបាល ហើយថវិកាដែលផាកបាននោះត្រូវរក្សាទុកនៅសាលាឃុំដើម្បីចាត់ចែងក្នុងការបើកវគ្គផ្សព្វផ្សាយពីផលប៉ះពាល់ការប្រើប្រាស់គ្រឿងស្រវឹង និង ចាត់ចែងក្នុងការលើកទឹកចិត្តដល់អ្នកដែលឈប់ប្រើប្រាស់គ្រឿងស្រវឹង ។

**ប្រការ១០៖**អជ្ញាធរមូលដ្ឋានមានមេភូមិ មាជិកក្រុមប្រឹក្សាឃុំ ប៉ូលីសប៉ុស្តិ៍រដ្ឋបាល គ្រូបង្រៀន បុគ្គលិកសុខាភិបាល យុវជន គណៈកម្មការអាចារ្យ និង ព្រះសង្ឃត្រូវចូលរួមផ្សព្វផ្សាយដល់ប្រជាជនក្នុងសហគមន៍ឲ្យបានជ្រួតជ្រាប ។

**ប្រការ១១៖** ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅឃុំសង្កែ ,ថ្ងៃទី...១០.....ខែ.កក្កដា.......ឆ្នាំ២០១៥

មេឃុំ

ម៉ៅ សានាំង